**Koh Santepheap Daily, Thursday 12th June 2014 (Page 13 & 19)**

# ប្រពៃណីតុបតែងផ្កាដ៏ល្បីល្បាញរបស់ជប៉ុនបង្ហាញនៅស្ថានទូត

**រាជធានីភ្នំពេញ ៖** កាលពីរសៀលថ្ងៃទី ១០ មិថុនា ២០១៤ ស្ថានទូតជប៉ុនបានរៀបចំធ្វើបទបង្ហាញពីប្រពៃណីតុបតែងផ្កា IKEBANA ដោយមានការចូលរួមពីភ្ញៀវកិត្តិយសជាច្រើន ។ ពិធីនោះមានការចូលរួមពីសមាគមនារីអាស៊ានប្រចាំនៅកម្ពុជា និងភរិយាឯកអគ្គរាជទូតប្រចាំនៅកម្ពុជា ។

លោកគូម៉ាម៉ារូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា មានប្រសាសន៍ថា IKEBANA ជាការវេចខ្ចប់តុបតែងផ្កាប្រកបទៅដោយលក្ខណៈប្រពៃណីរបស់ប្រទេសជប៉ុន ហើយដែលត្រូវគេនិយមចូលចិត្តនៅប្រទេសជប៉ុនតាំងពីយូរឆ្នាំមកហើយសម្រាប់គោរព ថ្វាយដល់ព្រះពុទ្ធរូប និងក្រោយមកទៀតត្រូវបានទទួលយកដើម្បីគោរពលំដាប់ធំមួយនៅក្នុងចំណោមអ្នកមានឋានៈខ្ពង់ខ្ពស់ តែក្រោយមកទៀតត្រូវបានគេយកមកអនុវត្តនៅក្នុងសង្គមទូទៅ ។ នៅក្នុងចំណោមសាលារៀន ផ្សេងៗអំពី IKEBANA នេះ សាលា Sogetsu ជាសាលាមួយដែលទទួលបានជម្រើសមួយល្អពោរពេញទៅដោយការច្នៃប្រឌិត ដែលមិនត្រឹមតែអនុវត្តនៅក្នុងប្រទេសជប៉ុនប៉ុណ្ណោះទេ ថែមទាំងត្រូវបានគេអនុវត្ត ទូទាំងសាកលលោក នាពេលបច្ចុប្បន្ន ។

លោកឯកអគ្គរាជទូតឱ្យដឹងថា លោកសាស្ត្រាចារ្យដ៏ល្បី គឺលោកដុកទ័រ SHINJI TSUKAWAKI ដែលជាគ្រូនៅសាលាសូគីសុ បានមកធ្វើបទបង្ហាញអំពីប្រពៃណីតុបតែងផ្កាជប៉ុន ។ លោកក៏ជាសាស្ត្រាចារ្យ នៅក្នុងវិទ្យាស្ថានបច្ចេកវិទ្យាធម្មជាតិនៅសាកលវិទ្យាល័យកាណាសាវ៉ារបស់ជប៉ុនផងដែរ ។

តាមរយៈការបង្ហាញពីលក្ខណៈពិសេសនៃវិធីរៀបចំផ្កា IKEBANA និងបង្ហាញអំពីអាថ៌កំបាំងនៃសោភ័ណភាពរបស់លោក SHINJI TSUKAWAKI លោកឯកអគ្គរាជទូតជប៉ុនសង្ឃឹមថា លោកជំទាវទាំងអស់ដែលចូលរួមក្នុងពិធី នឹងបានយល់ដឹង ព្រមទាំងចូលរួមអនុវត្តការរៀបចំផ្កា ។ លោកសង្ឃឹមថា លោកជំទាវ លោក លោកស្រីទាំងអស់ នឹងទទួលបានផលល្អមួយចំនួន ទីមួយគឺសិល្បៈនៃការរៀបចំផ្កា និងយល់ដឹងបន្ថែមទៀតអំពីវប្បធម៌របស់ប្រទេសជប៉ុន ។

លោក SHINJI TSUKAWAKI ថ្លែងថា

តទៅទំព័រ 19



លោក SHINJI TSUKAWAKI បង្ហាញពីប្រពៃណីតុបតែងផ្កា (រូបថត ខាត់ សាមឿន)

តមកពីទំព័រ 13

លោកមានជំនាញខាងផ្នែកតិចណូឡូជី ប៉ុន្តែលោកក៏ជាអ្នកជំនាញផ្នែកខាង ICC ជួយខាងផ្នែកមួយនៅអង្គរវត្តផងដែរ ។ លោកបានធ្វើកិច្ចការនៅក្នុងប្រទេសកម្ពុជារយៈពេល២៣ឆ្នាំមកហើយ ។ លោកមានសិស្សមករៀនពីលោកជាង៥០០នាក់នៅសាកលវិទ្យាល័យ ហើយក៏បានចូលរួមនៅក្នុងសមាគមន៍ ផ្សេងៗ ។

ក្នុងឱកាសនោះលោក SHINJI TSUKAWAKI បានបង្ហាញស្នាយពីការរៀបចំតែងលម្អផ្កាលក្ខណៈប្រពៃណីរបស់ជប៉ុនដ៏ល្បីល្បាញ ដែលមានលក្ខណៈខុសគ្នាពីការតុបតែងផ្ការបស់អឺរ៉ុប និងអាស៊ាន ៕

*ខាត់ សាមឿន*

